សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Royal University of Law and Economics

# គោលនយោបាយស្រាវជ្រាវ
# នៃ ស.ភ.ន.វ.ស

ឆ្នាំ២០១៥

# មាតិកា


**បុព្វកថា** ........ 1

**សេចក្តីផ្តើម** ........ 2

**ជំពូកទី១៖ គោលបំណងនៃគោលនយោបាយស្រាវជ្រាវ** ........ 3

**ជំពូកទី២៖ គណៈកម្មការគ្រប់គ្រងការស្រាវជ្រាវ** ........ 3

**ជំពូកទី៣៖ ប្រភេទនៃការស្រាវជ្រាវ** ........ 4

**ជំពូកទី៤៖ សហប្រតិបត្តិការលើការងារស្រាវជ្រាវ** ........ 4

**ជំពូកទី៥៖ ក្រមសីលធម៌នៃការស្រាវជ្រាវ** ........ 4

**ជំពូកទី៦៖ កម្មសិទ្ធិបញ្ញា** ........ 5

**ជំពូកទី៧៖ ការចងក្រង និងបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវ** ........ 5

**ជំពូកទី៨៖ និរន្តរភាពនៃការស្រាវជ្រាវ** ........ 6

**សេចក្តីសន្និដ្ឋាន** ........ 6

# បុព្វកថា

ការស្រាវជ្រាវមានសារៈសំខាន់ក្នុងការអភិវឌ្ឍសង្គមជាតិឲ្យមានការរីកចម្រើន។ សាកលវិទ្យាល័យល្បីៗនៅលើពិភពលោកបាន និងកំពុងផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការស្រាវជ្រាវរហូតដល់សាកលវិទ្យាល័យខ្លះបានក្លាយទៅជាសាកលវិទ្យាល័យស្រាវជ្រាវ។ ចំណែកសាស្ត្រាចារ្យដែលបង្រៀននៅតាមសាកលវិទ្យាល័យវិញ មិនមែនមានតួនាទីត្រឹមតែចែករំលែកចំណេះដឹងតាមរយៈការបង្រៀនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើការស្រាវជ្រាវយ៉ាងសកម្មទៀតផង។

នៅកម្ពុជា គ្រឹះស្ថានឧត្តមសិក្សាកំពុងត្រូវបានជំរុញឲ្យផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍការស្រាវជ្រាវ។ ជាក់ស្តែងនៅឆ្នាំ២០១២ គម្រោងលើកកម្ពស់សមត្ថភាព និងគុណភាពឧត្តមសិក្សាដែលគាំទ្រដោយធនាគារពិភពលោក សំដៅជួយបំប៉នសមត្ថភាពស្រាវជ្រាវរបស់សាស្ត្រាចារ្យ និងផ្តល់មូលនិធិស្រាវជ្រាវដល់គ្រឹះស្ថានឧត្តមសិក្សានៅព្រះរាជាណាចក្រកម្ពុជា តាមរយៈការសរសេរសំណើស្រាវជ្រាវដើម្បីប្រកួតប្រជែងយកមូលនិធិស្រាវជ្រាវ។ នៅឆ្នាំ២០១៥ ក្រសួងអប់រំ យុវជន និងកីឡាបានតម្រូវឲ្យគ្រឹះស្ថានឧត្តមសិក្សាទាំងអស់រៀបចំគោលនយោបាយស្រាវជ្រាវច្បាស់លាស់ ដើម្បីបង្កើនគុណភាពអប់រំឧត្តមសិក្សាសំដៅប្រកួតប្រជែងទីផ្សារការងារក្នុងតំបន់ និងលើពិភពលោក។

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានរៀបចំគោលនយោបាយស្រាវជ្រាវស្របតាមចក្ខុវិស័យ និងផែនការយុទ្ធសាស្ត្ររបស់ខ្លួន ក្នុងគោលបំណងជាចម្បងលើកកម្ពស់សមត្ថភាពស្រាវជ្រាវ និងបង្កើតវប្បធម៌ស្រាវជ្រាវដើម្បីផ្តល់ការអប់រំដែលមានគុណភាព និងមានការទទួលស្គាល់ជាលក្ខណៈជាតិ និងអន្តរជាតិ។ តាមរយៈគោលនយោបាយនេះសាកលវិទ្យាល័យនឹងជំរុញការស្រាវជ្រាវ និងការបោះពុម្ពផ្សាយឲ្យបានទូលំទូលាយ។

រាជធានីភ្នំពេញ ថ្ងៃទី ខែធ្នូ ឆ្នាំ២០១៥

**សាកលវិទ្យាធិការ**

# សេចក្តីផ្តើម

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចត្រូវបានបង្កើតឡើងដំបូងនៅឆ្នាំ១៩៤៩ ដែលមានឈ្មោះថាវិទ្យាស្ថានសិក្សាច្បាប់ និងសេដ្ឋកិច្ច។ ក្រោយមកសាកលវិទ្យាល័យនេះត្រូវបានផ្លាស់ប្តូរឈ្មោះជាបន្តបន្ទាប់ផ្អែកទៅតាមការវិវត្តនៃសង្គម និងរបបនយោបាយ ហើយនៅក្នុងឆ្នាំ១៩៩៤ បានប្រែក្លាយខ្លួនទៅជាមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោយមកទៀត បានប្រែក្លាយទៅជាសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចតាមអនុក្រឹត្យលេខ៥៦អនក្រ/បក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៣។ គួរកត់សម្គាល់ថា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានប្រែខ្លួនទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល តាមអនុក្រឹត្យលេខ៨៩អនក្រ/បក ចុថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧។ ក្នុងនាមគ្រឹះស្ថានឧត្តមសិក្សាដែលមានលក្ខណៈជាគ្រឹះស្ថានសាធារណៈរដ្ឋបាល សាកលវិទ្យាល័យបានដើរតួនាទីយ៉ាងសំខាន់ ជាថ្នាលបណ្តុះបណ្តាលនូវធនធាន មនុស្សដែលមានសក្តានុពលដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍជាតិតាមរយៈវិស័យអប់រំ។

សាកលវិទ្យាល័យមានតួនាទីសំខាន់បីរួមមាន៖ ការបង្រៀន ស្រាវជ្រាវ និងបម្រើសេវាសហគមន៍។ ដើម្បីបំពេញតួនាទីទាំងនេះឲ្យបានពេញលេញ ក៏ដូចជាចូលរួមចំណែកក្នុងការងារអភិវឌ្ឍលើវិស័យអប់រំ និងតាមរយៈគោលនយោបាយស្តីពីការអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំបានទទួលការឯកភាពក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំក្រសួងនាថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០, ផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំសម្រាប់ឆ្នាំ២០១១ដល់២០១៥ និងគោលនយោបាយស្តីពីការជំរុញកិច្ចការស្រាវជ្រាវសម្រាប់គ្រឹះស្ថានឧត្តមសិក្សា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានរៀបចំតាក់តែងឡើងនូវគោលនយោបាយស្រាវជ្រាវ ក្នុងគោលដៅដើម្បីសម្រេចឲ្យបានជាដាច់ខាតនូវការកសាងវប្បធម៌នៃការស្រាវជ្រាវវិទ្យាសាស្ត្រនៅក្នុងសាកលវិទ្យាល័យប្រកបដោយគុណភាព គំនិតច្នៃប្រឌិត និងការបង្កើតថ្មីស្របតាមការវិវត្តនៃសេដ្ឋកិច្ច និងសង្គមរបស់ប្រទេសកម្ពុជា ព្រមទាំងសំដៅជានាឲ្យបាននូវនិរន្តរភាពនៃកិច្ចដំណើការការងារបណ្តុះបណ្តាលធនធានមនុស្សប្រកប ដោយគុណភាព សមត្ថភាព សម្រាប់ជាសសរទ្រូងនៃការអភិវឌ្ឍជាតិនាពេលបច្ចុប្បន្ន និងបន្តទៀតនាពេលអនាគត។

# ជំពូកទី១
# គោលបំណងនៃគោលនយោបាយស្រាវជ្រាវ

គោលនយោបាយស្រាវជ្រាវនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចត្រូវបានបង្កើតឡើងក្នុងគោលបំណងដូចខាងក្រោម៖

- លើកកម្ពស់សមត្ថភាពនៃការសិក្សាស្រាវជ្រាវសម្រាប់បុគ្គលិក មន្ត្រីរាជការ និងសាស្ត្រាចារ្យ។
- លើកកម្ពស់គុណភាពអប់រំ និងនវានុវត្តន៍តាមរយៈការសិក្សាស្រាវជ្រាវលើគ្រប់មុខវិជ្ជា និងជំនាញដែលទាក់ទងទៅនឹងការបណ្តុះបណ្តាលនៅតាមមហាវិទ្យាល័យនីមួយៗ
- ជំរុញការស្រាវជ្រាវលើគ្រប់កម្រិត គ្រប់ប្រភេទទៅតាមជំនាញ និងវិជ្ជាជីវៈ ស្របតាមគោលនយោបាយនៃការអភិវឌ្ឍលើវិស័យអប់រំ ក្នុងទិសដៅសម្រេចឲ្យបាននូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។
- បង្កើតវប្បធម៌នៃការស្រាវជ្រាវដែលជាមូលដ្ឋានគ្រឹះនៃការប្រកួតប្រជែង និងការវាយតម្លៃក្នុងការផ្តល់ ឋានៈ កិត្តិយស កេរ្តិ៍ឈ្មោះសម្រាប់អ្នកស្រាវជ្រាវ បុគ្គលិក មន្ត្រីរាជការ សាស្ត្រាចារ្យ និងនិស្សិត។
- បោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវសម្រាប់អ្នកស្រាវជ្រាវ បុគ្គលិក មន្ត្រីរាជការ សាស្ត្រាចារ្យ និងនិស្សិត។

# ជំពូកទី២
# គណៈកម្មការគ្រប់គ្រងការស្រាវជ្រាវ

គណៈកម្មការគ្រប់គ្រងការស្រាវជ្រាវមានតួនាទីក្នុងការត្រួតពិនិត្យ វាយតម្លៃ និងសម្រេចលើសំណើស្រាវជ្រាវ និងស្នាដៃស្រាវជ្រាវគ្រប់ប្រភេទ រួមមានការស្រាវជ្រាវផ្នែកច្បាប់ ផ្នែកសេដ្ឋកិច្ច និងផ្នែកផ្សេងៗទៀតដែលបានដាក់ជូនដោយអ្នកស្រាវជ្រាវនៅ ស.ភ.ន.វ.ស។

គណៈកម្មការគ្រប់គ្រងការស្រាវជ្រាវនៃ ស.ភ.ន.វ.ស មានរចនាសម្ព័ន្ធដូចខាងក្រោម៖

- គណៈកម្មការគ្រប់គ្រងរួមលើការស្រាវជ្រាវមានតួនាទីពិនិត្យ និងសម្រេចលើសំណើស្រាវជ្រាវ និងស្នាដៃស្រាវជ្រាវគ្រប់ប្រភេទដែលបានត្រួតពិនិត្យ និងវាយតម្លៃដោយអនុគណៈកម្មការបច្ចេកទេស។
- អនុគណៈកម្មការបច្ចេកទេសមានតួនាទីត្រួតពិនិត្យ និងវាយតម្លៃលើសំណើស្រាវជ្រាវ និងស្នាដៃស្រាវជ្រាវទៅតាមជំនាញនៅ ស.ភ.ន.វ.ស ដែលដាក់ជូនដោយអ្នកស្រាវជ្រាវ ឬក្រុមអ្នកស្រាវជ្រាវ។

សមាសភាពនៃគណៈកម្មការគ្រប់គ្រងរួមលើការស្រាវជ្រាវ និងបណ្តាអនុគណៈកម្មការបច្ចេកទេស ព្រមទាំងនីតិវិធីនៃការត្រួតពិនិត្យ ការវាយតម្លៃ និងសម្រេចលើសំណើស្រាវជ្រាវ និងស្នាដៃស្រាវជ្រាវ មានកំណត់នៅក្នុងគោលការណ៍ណែនាំដោយឡែកដែលអនុម័តដោយ ស.ភ.ន.វ.ស។

## ជំពូកទី៣
## ប្រភេទនៃការស្រាវជ្រាវ

ស.ភ.ន.វ.ស បើកទូលាយឲ្យមានការចូលរួមស្រាវជ្រាវជាបុគ្គល ឬរួមគ្នារវាងអ្នកស្រាវជ្រាវ បុគ្គលិក មន្ត្រីរាជការ និងសាស្ត្រាចារ្យនៃស.ភ.ន.វ.ស និងស្ថាប័នស្រាវជ្រាវនានា ជាពិសេសវិស័យឯកជន និងសាធារណៈ ទាំងអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិ។

ស.ភ.ន.វ.ស ទទួលយកនូវស្នាដៃស្រាវជ្រាវគ្រប់ប្រភេទ រួមមានការស្រាវជ្រាវផ្នែកច្បាប់ សេដ្ឋកិច្ច និងការស្រាវជ្រាវផ្សេងៗទៀត ដោយអាស្រ័យទៅតាមទំហំ និងប្រភេទនៃការស្រាវជ្រាវ រួមមានការស្រាវជ្រាវរយៈពេលខ្លី (៣ខែទៅ៦ខែ) ការស្រាវជ្រាវរយៈពេលមធ្យម (៦ខែទៅ១៨ខែ) និងការស្រាវ ជ្រាវរយៈពេលវែង (១៨ខែឡើងទៅ)។

សេចក្តីណែនាំលំអិតអំពីប្រភេទនៃការស្រាវជ្រាវត្រូវកំណត់ដោយឡែកដោយ ស.ភ.ន.វ.ស។

## ជំពូកទី៤
## សហប្រតិបត្តិការលើការងារស្រាវជ្រាវ

ដើម្បីលើកកម្ពស់គុណភាព និងសមត្ថភាពស្រាវជ្រាវឲ្យកាន់តែទូលំទូលាយ ស.ភ.ន.វ.ស ជំរុញឲ្យមានកិច្ចសហការជាមួយគ្រឹះស្ថានជាតិ និងអន្តរជាតិលើការស្រាវជ្រាវរួមគ្នា។ លើសពីនេះ ស.ភ.ន.វ.ស លើកទឹកចិត្តឲ្យមានកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិតាមរយៈការចែករំលែកចំណេះដឹង បទពិសោធន៍ និងលទ្ធផលស្រាវជ្រាវ ដោយរៀបចំសិក្ខាសាលា ឬសន្និសីទថ្នាក់ជាតិ និងអន្តរជាតិរួមគ្នា។

## ជំពូកទី៥
## ក្រមសីលធម៌នៃការស្រាវជ្រាវ

- ស.ភ.ន.វ.ស រៀបចំគោលការណ៍ណែនាំ និងផ្តល់ព័ត៌មានដល់និស្សិត បុគ្គលិក និងអ្នកសិក្សាស្រាវជ្រាវអំពីក្រមសីលធម៌នៃការស្រាវជ្រាវ និងគុណប្រយោជន៍នៃស្នាដៃស្រាវជ្រាវ។
- ស.ភ.ន.វ.ស យកចិត្តទុកដាក់ និងគោរពដល់ក្រមសីលធម៌នៃការស្រាវជ្រាវដែលមាននៅក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ។

- ស.ភ.ន.វ.ស រៀបចំអភិវឌ្ឍនីតិវិធីនៃការត្រួតពិនិត្យលើស្នាដៃស្រាវជ្រាវ ក្នុងគោលដៅបង្ការមិនឲ្យមានការលួចចម្លងស្នាដៃស្រាវជ្រាវ ដើម្បីធានាឲ្យបាននូវការអនុវត្តគោលការណ៍ណែនាំស្ដីគុណធម៌នៃការស្រាវជ្រាវ។

## ជំពូកទី៦
## កម្មសិទ្ធិបញ្ញា

ដើម្បីធានាឲ្យបាននូវនិរន្តរភាពនៃការអនុវត្តគោលការណ៍ណែនាំស្ដីពីកម្មសិទ្ធិបញ្ញា និងអភិបាលកិច្ចលើការស្រាវជ្រាវ ស.ភ.ន.វ.ស មានសិទ្ធិស្វែងរកកម្រៃ និងផលប្រយោជន៍ផ្សេងៗ ពីអាជ្ញាប័ណ្ណកម្មសិទ្ធិបញ្ញាលើរាល់ស្នាដៃស្រាវជ្រាវគ្រប់ប្រភេទដែលទាក់ទងទៅនឹងនវានុវត្ត និងការបង្កើតស្នាដៃថ្មីៗទៀតក្នុងនាមជាទីប្រឹក្សាបច្ចេកទេស ឬជាសហកម្មសិទ្ធិលើស្នាដៃស្រាវជ្រាវអាស្រ័យទៅតាមកិច្ចសន្យា។

ស.ភ.ន.វ.ស កំណត់ថា ស្នាដៃស្រាវជ្រាវគ្រប់ប្រភេទត្រូវស្ថិតនៅក្រោមកម្មសិទ្ធិបញ្ញា និងការគ្រប់គ្រងរបស់ ស.ភ.ន.វ.ស តាមរយៈការត្រួតពិនិត្យ និងវាយតម្លៃពីអនុគណៈកម្មការបច្ចេកទេស ដោយផ្អែកលើគោលការណ៍ណែនាំស្ដីពីកម្មសិទ្ធិបញ្ញា។

អនុគណៈកម្មការបច្ចេកទេសមានតួនាទីត្រួតពិនិត្យ និងវាយតម្លៃលើស្នាដៃស្រាវជ្រាវគ្រប់ប្រភេទ ក្នុងគោលបំណងការពារមិនឲ្យមានការលួចចម្លងស្នាដៃ និងការបំពានទៅលើគោលការណ៍ណែនាំស្ដីពីកម្មសិទ្ធិបញ្ញា។

សមាសភាពនៃអនុគណៈកម្មការបច្ចេកទេស និងនីតិវិធីនៃការត្រួតពិនិត្យ វាយតម្លៃលើស្នាដៃស្រាវជ្រាវគ្រប់ប្រភេទដែលពាក់ព័ន្ធទៅនឹងកម្មសិទ្ធិបញ្ញា បានកំណត់ក្នុងគោលការណ៍ណែនាំដោយឡែកអនុម័តដោយ ស.ភ.ន.វ.ស ដូចមានចែងនៅក្នុងជំពូកទី២ស្ដីពីគណៈកម្មការគ្រប់គ្រងការស្រាវជ្រាវ។

## ជំពូកទី៧
## ការចងក្រង និងបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវ

ដើម្បីការពារស្នាដៃ និងចូលរួមចំណែកក្នុងការកសាងឯកសារស្រាវជ្រាវ ស.ភ.ន.វ.ស ចងក្រងស្នាដៃស្រាវជ្រាវដូចជា ព្រឹត្តិបត្រ ទស្សនាវដ្ដីបច្ចេកទេសជាតិ និងអន្តរជាតិ សៀវភៅបង្រៀន និងសៀវភៅមេរៀន ស្របតាមកម្មវិធីបណ្ដុះបណ្ដាលរបស់ ស.ភ.ន.វ.ស ហើយព្រមទាំងធ្វើការផ្សព្វផ្សាយនូវស្នាដៃទាំងអស់នោះឲ្យបានទូលំទូលាយតាមប្រព័ន្ធអេឡិចត្រូនិច (e-library) និងតម្កល់ស្នាដៃស្រាវជ្រាវទាំងអស់នៅក្នុងបណ្ណាល័យសម្រាប់អ្នកសិក្សាស្រាវជ្រាវបន្ត។

# ជំពូកទី៨
# និរន្តរភាពនៃការស្រាវជ្រាវ

ដើម្បីធានាឲ្យបាននិរន្តរភាពនៃការស្រាវជ្រាវ ស.ភ.ន.វ.ស រៀបចំឲ្យមានជាការបណ្តុះបណ្តាលបន្ត និងទស្សនកិច្ចសិក្សាស្រាវជ្រាវ ដើម្បីស្វែងយល់ពីការអភិវឌ្ឍនៃសាកលវិទ្យាល័យដៃគូរដល់បុគ្គលិក សាស្ត្រាចារ្យ មន្ត្រីរាជការ និងអ្នកសិក្សាស្រាវជ្រាវផ្សេងទៀត។

ដើម្បីធានាឲ្យបាននូវគុណភាព និងជំរុញឲ្យមានការងារស្រាវជ្រាវ ស.ភ.ន.វ.ស មានកញ្ចប់ថវិកាសម្រាប់ការស្រាវជ្រាវ។

# សេចក្តីសន្និដ្ឋាន

គោលនយោបាយស្រាវជ្រាវនៃ ស.ភ.ន.វ.ស.បានចូលរួមចំណែកយ៉ាងសកម្មក្នុងការធានាគុណភាពអប់រំ និងនវានុវត្តនៅព្រះរាជាណាចក្រកម្ពុជា តាមរយៈការបង្កើតឲ្យមាននូវវប្បធម៌ស្រាវជ្រាវដែលបានផ្តល់នូវគុណប្រយោជន៍ជាចម្បងលើការអភិវឌ្ឍគុណភាពសមត្ថភាពឲ្យបានទូលំទូលាយ រួមមានការលើកកម្ពស់គុណភាពសមត្ថភាពស្រាវជ្រាវគ្រប់ជំនាញ ប្រកបដោយគំនិតច្នៃប្រឌិតស្របតាមការវិវត្តនៃសេដ្ឋកិច្ច និងសង្គមនៅកម្ពុជានាពេលបច្ចុប្បន្ន ទាំងនេះគឺបានធានានូវនិរន្តរភាពនៃកិច្ចដំណើការការងារបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយគុណភាពសមត្ថភាព។ ដូចនេះបុគ្គលិក សាស្ត្រាចារ្យ មន្ត្រីរាជការ និងនិស្សិតនៅសាកលវិទ្យាល័យត្រូវចូលរួមចំណែកអនុវត្ត និងផ្សព្វផ្សាយនូវគោលនយោបាយស្រាវជ្រាវនេះឲ្យកាន់តែទូលំទូលាយ និងលើកទឹកចិត្តដើម្បីចូលរួមអនុវត្តឲ្យបានជោគជ័យ សម្រាប់ចូលរួមដំណើរការអភិវឌ្ឍជាតិក្រោមក្របខ័ណ្ឌនៃសកលភាវូបនីយកម្ម និងសមាហរណកម្មនាពេលអនាគត។